**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតមេត្តាជ្រាបថា ដោយក្តាប់ជាប់នូវស្ថានភាពជាក់ស្តែង តម្រូវការចាំបាច់ និងកង្វល់របស់បងប្អូនកម្មករនិយោជិតនៅរោងចក្រចំនួន៩ ដែលបានបិទទ្វារដោយម្ចាស់រត់ចោលនោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់បុរេប្រទានថវិកាចំនួន ៤.៥៧៩.៨៨៤ដុល្លារអាមេរិក សម្រាប់ទូទាត់ប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ជូនកម្មករនិយោជិតចំនួន ៤.១៤៦នាក់ នៅរោងចក្រចំនួន៩ ក្នុងនោះនៅខេត្តកណ្តាលចំនួន១ ខេត្តកំពង់ស្ពឺចំនួន៣ និងរាជធានីភ្នំពេញចំនួន៥។

រាជរដ្ឋាភិបាលបានផ្តល់គោលការណ៍ក្នុងការដោះស្រាយករណីរោងចក្របិទទ្វារដោយម្ចាស់រត់ចោលដូចខាងក្រោមៈ

១. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងចាត់វិធានការដោះស្រាយជាបន្ទាន់នូវរាល់ករណីរោងចក្របិទទ្វារដោយម្ចាស់រត់ចោល ដោយធ្វើការបើកផ្តល់ប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ ជូនបងប្អូនកម្មករនិយោជិតឱ្យបានទាន់ពេលវេលាស្របតាមច្បាប់ជាធរមាន។

២. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា នឹងចាត់វិធានការរឹបអូសទ្រព្យសម្បត្តិរបស់រោងចក្រ ដើម្បីលក់ឡៃឡុងយកថវិកាមកបើកផ្តល់ជូនកម្មករនិយោជិត ឬទូទាត់សងថវិកាជាតិវិញ តាមនីតិវិធី ២គឺៈ

ក.ចំពោះក្រុមហ៊ុនដែលដួលរលំបិទទ្វារ ហើយម្ចាស់ ឬតំណាងក្រុមហ៊ុននៅមានវត្តមានដោះស្រាយទៅតាមនីតិវិធីសម្របសម្រួលគ្នារវាងគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសគឺម្ចាស់ ឬតំណាងក្រុមហ៊ុន ជាមួយនឹងកម្មករនិយោជិត។

ខ.ចំពោះក្រុមហ៊ុនដួលរលំបិទទ្វារ ហើយម្ចាស់ ឬតំណាងក្រុមហ៊ុននៅមានវត្តមាន ប៉ុន្តែគ្មានប្រាក់ដោះស្រាយ ឬអវត្តមានម្ចាស់ក្រុមហ៊ុន ឬតំណាងក្រុមហ៊ុន ក្រសួងនឹងអនុវត្តតាមនីតិវិធីតុលាការ។

៣. ទីភ្នាក់ងារជាតិមុខរបរ និងការងារ នឹងចុះឈ្មោះរកការងារថ្មីជូនកម្មករនិយោជិតដែលបានបាត់បង់ការងារ។

៤. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា សហការជាមួយនគរបាលយុត្តិធម៌ និងព្រះរាជអាជ្ញា ដើម្បីកោះអញ្ជើញ ឬឃាត់ខ្លួនម្ចាស់ ឬតំណាងក្រុមហ៊ុនដែលប្រព្រឹត្តិល្មើសច្បាប់រត់ចោលក្រុមហ៊ុន ព្រមទាំងកំពុងចាត់វិធានការតាមផ្លូវច្បាប់ចំពោះបុគ្គល ដែលផ្តល់ប្រឹក្សាយោបល់បែបទុច្ចរិតដល់ម្ចាស់ ឬតំណាងក្រុមហ៊ុនឱ្យជ្រើសរើសវិធីសាស្រ្តបិទទ្វាររោងចក្រដោយរត់ចោលកម្មករនិយោជិត ទៅតាមច្បាប់ជាធរមាន។

៥. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងរៀបចំបទប្បញ្ញត្តិកំណត់កាតព្វកិច្ចឱ្យក្រុមហ៊ុនត្រូវមានធានារ៉ាប់រងហានិភ័យប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗរបស់កម្មករនិយោជិត ហើយបញ្ចូលទៅក្នុងបញ្ជីត្រួតពិនិត្យរបស់អធិការកិច្ចការងារ និងចាត់វិធានការម៉ឺងម៉ាត់តាមផ្លូវច្បាប់ជាធរមាន។

៦-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំបទប្បញ្ញតិស្តីពីការទូទាត់ប្រចាំឆ្នាំនូវប្រាក់អតីតភាពប្រចាំឆ្នាំដើម្បីបន្ថយទំហំទឹកប្រាក់សរុបនៃការទូទាត់សរុបលើប្រាក់អត្ថប្រយោជន៍ ក្នុងករណីរោងចក្របិទទ្វារជាយថាហេតុ។

សេចក្តីដូចបានជម្រាបជូនខាងលើសូមសាធារណជន ជាពិសេសបងប្អូន កម្មករនិយោជិតមេត្តាជ្រាបជាព័ត៌មានតាមការគួរ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១៨

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩